# សេចក្តីជូនដំណឹងជូនចំពោះអ្នកជាប់កិច្ចសន្យា 1099-MISC

*អង្គភាពដែលត្រូវបានរ៉ាប់រងដែលមានកម្មករនិយោជិតតិចជាង 25 នាក់*

## សិទ្ធិ និងកាតព្វកិច្ចនៅក្រោមច្បាប់ឈប់សម្រាកដោយមូលហេតុគ្រួសារ និងវេជ្ជសាស្ត្រនៃរដ្ឋម៉ាសាឈូសេត M.G.L. c. 175M

______________________________
(ឈ្មោះនិយោជក)

______________________________
(អាសយដ្ឋានលើផ្លូវរបស់និយោជក)

______________________________
(ទីក្រុង រដ្ឋ លេខកូដប្រៃសណីយ៍សម្គាល់តំបន់របស់និយោជក)

______________________________
(លេខអត្តសញ្ញាណនិយោជក) (FEIN)

នៅក្រោមច្បាប់ឈប់សម្រាកដោយសារមូលហេតុគ្រួសារ និងវេជ្ជសាស្ត្ររបស់រដ្ឋម៉ាសាឈូសេត M.G.L. c. 175M **អង្គភាពអាជីវកម្មដែលត្រូវបានរ៉ាប់រង** ត្រូវបានតម្រូវទាមទារឲ្យផ្តល់ដល់អ្នកជាប់កិច្ចសន្យាម្នាក់ៗនៃអ្នកជាប់កិច្ចសន្យា 1099-MISC របស់ខ្លួន នៅពេលដែលកិច្ចសន្យាត្រូវបានធ្វើឡើងនូវព័ត៌មានដែលត្រូវបានចែងនៅក្នុងសេចក្តីជូនដំណឹងនេះ។

**អង្គភាពអាជីវកម្មដែលត្រូវបានរ៉ាប់រង** គឺជាអាជីវកម្ម ឬជំនួញដែលចុះកិច្ចសន្យាជាមួយបុគ្គលដែលធ្វើការរកស៊ីខ្លួនឯងដើម្បីបានសេវាកម្ម ហើយត្រូវបានតម្រូវទាមទារឲ្យរាយការណ៍ការបង់ទូទាត់ទៅកាន់បុគ្គលបែបនោះនៅលើទម្រង់បែបបទ IRS 1099-MISC ***សម្រាប់លើសពី 50 ភាគរយនៃកម្លាំងពលកម្មរបស់ពួកគេ។***

**អង្គភាពនេះ៖**

- ☐ **គឺជា** អង្គភាពអាជីវកម្មដែលត្រូវបានរ៉ាប់រងនៅក្រោមច្បាប់
- ☐ **មិនមែនជា** អង្គភាពអាជីវកម្មដែលត្រូវបានរ៉ាប់រងនៅក្រោមច្បាប់ទេ

ប្រសិនបើអង្គភាពនេះគឺជា **អង្គភាពអាជីវកម្មដែលត្រូវបានរ៉ាប់រង** វាត្រូវបានតម្រូវទាមទារនៅក្រោមច្បាប់ឲ្យធ្វើវិភាគទានតាងនាមជំនួសឲ្យអ្នកជាប់កិច្ចសន្យា 1099-MISC របស់ខ្លួនហាក់បីដូចជាពួកគេជានិយោជិតដូចដែលបាននិយាយគូសសំខាន់ៗត្រួសៗខាងក្រោម។ យោងទៅតាមនោះ ប្រសិនបើអាជីវកម្មនេះជាអង្គភាពអាជីវកម្មដែលត្រូវបានរ៉ាប់រង អ្នកអាចនឹងមានសិទ្ធិសក្តិសមសម្រាប់ការប្តូរជំនួសប្រាក់ចំណូលនៅក្នុងកាលៈទេសៈខ្លះដូចដែលបាននិយាយគូសសំខាន់ត្រួសៗខាងក្រោមនៅក្នុងផ្នែកដែលមានចំណងជើងថា "**សេចក្តីពន្យល់នៃអត្ថប្រយោជន៍**"។

ប្រសិនបើអង្គភាពនេះមិនមែនជាអង្គភាពអាជីវកម្មដែលត្រូវបានរ៉ាប់រងទេ អ្នកក៏នៅតែអាចនឹងជ្រើសរើសដើម្បីក្លាយជាបុគ្គលឯកត្តជនដែលត្រូវបានរ៉ាប់រងដែលនៅក្រោមច្បាប់ឈប់សម្រាកដោយសារមូលហេតុគ្រួសារ និងវេជ្ជសាស្ត្រ។ ប្រសិនបើអ្នកជ្រើសរើសធ្វើដូចនោះ សូមមើល សេចក្តីជូនដំណឹងពីការធ្វើជម្រើសរបស់អ្នករកស៊ីដោយខ្លួនឯង សម្រាប់ព័ត៌មានបន្ថែមទៀត។

## សេចក្ដីពន្យល់នៃអត្ថប្រយោជន៍

- **ដោយចាប់ផ្ដើមនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2021** អ្នកអាចនឹងមានសិទ្ធិសក្តិសមទទួលបានរហូតដល់
    - 12 សប្ដាហ៍នៃច្បាប់ឈប់សម្រាកដោយមូលហេតុក្រុមគ្រួសារដោយមានប្រាក់ខែនៅក្នុងឆ្នាំអត្ថប្រយោជន៍សម្រាប់ការផ្ដល់កំណើត ការយកមកចិញ្ចឹមធ្វើកូន ឬការដាក់ឲ្យចិញ្ចឹមបីបាច់ថែរក្សានៃកូន ឬដោយសារតែសភាពចាំបាច់បន្ទាន់ដែលធ្វើឲ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលកើតចេញមកពីការពិតដែលថាសមាជិកក្រុមគ្រួសារកំពុងជាប់ភារកិច្ចសកម្មក្នុងទ័ព ឬត្រូវបានជូនដំណឹងនូវការអំពាវនាវដែលនឹងកើតឡើងឲ្យចូលបំពេញភារកិច្ចសកម្មក្នុងកងកម្លាំងប្រដាប់អាវុធ។
    - 20 សប្ដាហ៍នៃច្បាប់ឈប់សម្រាកដោយមូលហេតុវេជ្ជសាស្រ្តដោយមានប្រាក់ខែនៅក្នុងឆ្នាំអត្ថប្រយោជន៍ ប្រសិនបើពួកគេមានសភាពសុខភាពធ្ងន់ធ្ងរដែលធ្វើឲ្យពួកគេលែងមានសមត្ថភាពធ្វើការងារបាន។
    - 26 សប្ដាហ៍នៃច្បាប់ឈប់សម្រាកដោយមូលហេតុក្រុមគ្រួសារដោយមានប្រាក់ខែនៅក្នុងឆ្នាំអត្ថប្រយោជន៍ដើម្បីមើលថែទាំសមាជិកក្រុមគ្រួសារដែលជាសមាជិកជួរកងទ័ពដែលត្រូវបានរ៉ាប់រងដែលឆ្លងកាត់ការព្យាបាល វេជ្ជសាស្រ្ត ឬមិនដូចនោះទេ ដែលដោះស្រាយចាត់ចែងជាមួយវិបាកនៃសភាពសុខភាពធ្ងន់ធ្ងរដែលទាក់ទងនឹងការបម្រើយោធារបស់សមាជិកក្រុមគ្រួសារ។
- **ចាប់ផ្ដើមនៅថ្ងៃទី 1 កក្កដា ឆ្នាំ 2021** អ្នកអាចនឹងមានសិទ្ធិសក្តិសមទទួលបានរហូតដល់
    - 12 សប្ដាហ៍នៃច្បាប់ឈប់សម្រាកដោយមូលហេតុក្រុមគ្រួសារដោយមានប្រាក់ខែនៅក្នុងឆ្នាំអត្ថប្រយោជន៍ដើម្បីថែទាំសមាជិកក្រុមគ្រួសារដែលមានសភាពសុខភាពធ្ងន់ធ្ងរ។
    - 26 សប្ដាហ៍សរុប ជាការបូកផ្សំបញ្ចូលគ្នា នៃច្បាប់ឈប់សម្រាកដោយមូលហេតុគ្រួសារ និងវេជ្ជសាស្ត្រដោយមានគិតប្រាក់ខែជូននៅក្នុងឆ្នាំអត្ថប្រយោជន៍មួយ។
- **ចំនួននៃប្រាក់អត្ថប្រយោជន៍ប្រចាំសប្ដាហ៍របស់អ្នក** នឹងផ្អែកលើចំណូលរកបានរបស់និយោជិត ដោយមានអត្ថប្រយោជន៍អតិបរមាចំនួន $850 ក្នុងមួយសប្ដាហ៍។

## វិភាគទានទៅក្នុងមូលនិធិអាណត្តិព្យាបាលភាពសន្តិសុខការងាររបស់ក្រសួងច្បាប់ឈប់សម្រាកដោយសារហេតុផលគ្រួសារ និងវេជ្ជសាស្ត្រ

នៅថ្ងៃទី 1 ខែតុលា ឆ្នាំ 2019 វិភាគទានចូលរួមទៅក្នុងមូលនិធិអាណត្តិព្យាបាលភាពគ្រួសារ និងសន្តិសុខការងាររបស់ក្រសួងច្បាប់ឈប់សម្រាកដោយសារហេតុផលគ្រួសារ និងវេជ្ជសាស្ត្រ (DFML) នឹងចាប់ផ្ដើម។ **អង្គភាពអាជីវកម្មដែលត្រូវបានរ៉ាប់រង** ត្រូវបានតម្រូវទាមទារឲ្យផ្ញើវិភាគទានទៅកាន់ DFML សម្រាប់គ្រប់បុគ្គលដែលធ្វើការរកស៊ីខ្លួនឯង 1099-MISC ទាំងអស់នៅក្នុងកម្លាំងពលកម្មរបស់ខ្លួនប្រសិនបើបុគ្គលដែលធ្វើការរកស៊ីខ្លួនឯងទាំងនោះផ្សំបង្កើតបានលើសពី 50 ភាគរយនៃកម្លាំងពលកម្មរបស់ខ្លួន។ អត្រាវិភាគទានអាចនឹងត្រូវបានលៃតម្រូវរាល់ឆ្នាំ ហើយអាចរកបាននៅក្នុងសេចក្តីជូនដំណឹងពីអត្រាដែលចាប់មានប្រសិទ្ធភាពដែលភ្ជាប់មកជាមួយ។

## របៀបដាក់ការទាមទារសំណង

បុគ្គលដែលត្រូវបានរ៉ាប់រងត្រូវតែដាក់ការទាមទារសំណងសម្រាប់ការប្ដូរជំនួសប្រាក់ចំណូលគ្រួសារ និងវេជ្ជសាស្ត្រដែលត្រូវបានបង់ថ្លៃជូនជាមួយ DFML ដោយប្រើប្រាស់ទម្រង់បែបបទរបស់ក្រសួងនេះ។ ទម្រង់បែបបទ និងសេចក្ដីណែនាំរបស់ការទាមទារសំណងនឹងអាចរកបាននៅលើគេហទំព័ររបស់ក្រសួង www.mass.gov/DFML មុនខែ មករា ឆ្នាំ 2021 ពេលដែលអត្ថប្រយោជន៍មានជាលើកដំបូង។

អ្នកជាប់កិច្ចសន្យា 1099-MISC ត្រូវបានតម្រូវឲ្យផ្ដល់ការជូនដំណឹងយ៉ាងហោចណាស់ 30 ថ្ងៃទៅកាន់អង្គភាពអាជីវកម្មដែលត្រូវបានរ៉ាប់រងនូវកាលបរិច្ឆេទចាប់ផ្ដើមដែលរំពឹងទុកនៃច្បាប់ឈប់សម្រាកណាមួយ រយៈកាលដែលរំពឹងទុកនៃច្បាប់ឈប់សម្រាកណាមួយ និងកាលបរិច្ឆេទរំពឹងទុកនៃការវិល

គ្រលប់មកវិញ។ អ្នកជាប់កិច្ចសន្យា 1099-MISC ដែលមិនអាចផ្តល់ការជូនដំណឹង 30 ថ្ងៃបានដោយសារកាលៈទេសៈហួសពីការគ្រប់គ្រងបានរបស់គេ ត្រូវបានតម្រូវឲ្យផ្តល់ការជូនដំណឹងឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## ការលើកលែងចំពោះគម្រោងធានារ៉ាប់រងឯកជន

អង្គភាពអាជីវកម្មដែលត្រូវបានរ៉ាប់រងដែលផ្តល់នូវច្បាប់ឈប់សម្រាកដែលមានគិតប្រាក់ខែជូនដោយមានអត្ថប្រយោជន៍ដែលយ៉ាងហោចណាស់ច្រើនដូចទៅនឹងអត្ថប្រយោជន៍អស់ទាំងឡាយណាដែលត្រូវបានផ្តល់ជូននៅក្រោមច្បាប់ អាចនឹងដាក់ពាក្យសុំការលើកលែងពីការបង់វិភាគទានមូលនិធិអាណត្តិព្យាបាលភាពគ្រួសារ និងសន្តិសុខការងាររបស់ក្រសួងច្បាប់ឈប់សម្រាកដោយសារមូលហេតុគ្រួសារ និងវេជ្ជសាស្ត្របាន។ អង្គភាពអាជីវកម្មដែលត្រូវបានរ៉ាប់រងអាចនឹងដាក់ពាក្យសុំការលើកលែងពីវិភាគទានសម្រាប់ច្បាប់ឈប់សម្រាកដោយមូលហេតុវេជ្ជសាស្ត្រ  វិភាគទានសម្រាប់ច្បាប់ឈប់សម្រាកដោយមូលហេតុគ្រួសារ ឬទាំងពីរបាន។

សេចក្តីលម្អិតនៃគម្រោងធានារ៉ាប់រងឯកជនណាមួយត្រូវតែផ្តល់ទៅឲ្យអ្នកជាប់កិច្ចសន្យា 1099-MISC ដោយអង្គភាពអាជីវកម្មដែលត្រូវបានរ៉ាប់រងនៅពេលជាមួយគ្នាដូចនឹងសេចក្តីជូនដំណឹងនេះដែរ។

______________________________
(ឈ្មោះនិយោជក)

- ☐ មិនមានគម្រោងធានារ៉ាប់រងឯកជនដែលត្រូវបានអនុម័តព្រមទេ
- ☐ មានគម្រោងធានារ៉ាប់រងឯកជនដែលត្រូវបានអនុម័តសម្រាប់ទាំងច្បាប់ឈប់សម្រាកដោយមូលហេតុគ្រួសារ និងវេជ្ជសាស្ត្រ
- ☐ មានគម្រោងធានារ៉ាប់រងឯកជនដែលត្រូវបានអនុម័តសម្រាប់ច្បាប់ឈប់សម្រាកដោយមូលហេតុគ្រួសារតែប៉ុណ្ណោះ
- ☐ មានគម្រោងធានារ៉ាប់រងឯកជនដែលត្រូវបានអនុម័តសម្រាប់ច្បាប់ឈប់សម្រាកដោយមូលហេតុវេជ្ជសាស្ត្រតែប៉ុណ្ណោះ។

## ព័ត៌មានទំនាក់ទំនងរបស់ក្រសួងច្បាប់ឈប់សម្រាកដោយមូលហេតុគ្រួសារ និងវេជ្ជសាស្ត្រ


**Massachusetts Department of Family and Medical Leave** (ក្រសួងច្បាប់ឈប់សម្រាកដោយមូលហេតុគ្រួសារ និងវេជ្ជសាស្ត្រនៃរដ្ឋម៉ាសាឈូសេត)
Charles F. Hurley Building
19 Staniford Street, 1st Floor
Boston, MA 02114
(617) 626-6565
www.mass.gov/DFML


## មានព័ត៌មានបន្ថែមទៀត

សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមចូលទៅមើលគេហទំព័ររបស់ក្រសួង៖ **www.mass.gov/DFML**។

# ការទទួលស្គាល់

ហត្ថលេខាអ្នកខាងក្រោមបានទទួលស្គាល់នូវការទទួលបានព័ត៌មានខាងលើដោយអ្នកហើយនៅពេលដែលកិច្ចសន្យារបស់អ្នកត្រូវបានធ្វើឡើង ឬនៅមុនថ្ងៃទី 1 តុលា ឆ្នាំ 2019 មួយណាក៏ដោយឲ្យតែនៅក្រោយជាងគេ។

______________________________ ______________

**ហត្ថលេខា** **កាលបរិច្ឆេទ**

______________________________

**ឈ្មោះ (សំណេរអក្សរពុម្ព)**

ការទទួលស្គាល់ដែលត្រូវបានចុះហត្ថលេខារបស់អ្នកនឹងត្រូវបានរក្សាទុកដោយអង្គភាពអាជីវកម្មដែលត្រូវបានរ៉ាប់រង។ សូមរក្សាទុកច្បាប់សំណៅមួយច្បាប់សម្រាប់ជាឯកសារសម្គាងរបស់អ្នកខ្លួនឯង។

**អត្រាមានប្រសិទ្ធភាព៖ ឆ្នាំ 2019**

*សម្រាប់និយោជកដែលមាននិយោជិតតិចជាង 25 នាក់*

| វិភាគទានសម្រាប់ច្បាប់ឈប់សម្រាក ដោយមូលហេតុគ្រួសារ | វិភាគទានសម្រាប់ច្បាប់ឈប់សម្រាក ដោយមូលហេតុវេជ្ជសាស្ត្រ | ចំនួនវិភាគទានសរុប |
|---|---|---|
| .13% | .248% | .378% |

នៅថ្ងៃទី 1 ខែតុលា ឆ្នាំ 2019 វិភាគទានទៅដល់មូលនិធិអាណត្តិព្យាបាលភាពសន្តិសុខការងាររបស់ក្រសួងច្បាប់ឈប់សម្រាកដោយ សារមូលហេតុគ្រួសារ និង វេជ្ជសាស្ត្រ (DFML) នឹងចាប់ផ្តើម។ និយោជកនឹងទទួលខុសត្រូវក្នុងការផ្ញើវិភាគទានទៅកាន់ DFML សម្រាប់និយោជិតទាំង អស់។

បច្ចុប្បន្ននេះ ចំនួនវិភាគទានសរុបគឺ 00.75% នៃប្រាក់ខែ។ ក្នុងចំណោមចំនួនវិភាគទានសរុបដែលស្មើនឹង 00.75% នោះ មានការញែកបែងចែក៖ 17.3% គឺវិភាគទានសម្រាប់ច្បាប់ឈប់សម្រាកដោយមូលហេតុគ្រួសារ និង 82.7% គឺវិភាគទានសម្រាប់ច្បាប់ឈប់សម្រាកដោយមូលហេតុវេជ្ជសាស្ត្រ។

សម្រាប់អង្គភាពអាជីវកម្មដែលត្រូវបានរ៉ាប់រងតូចតាច (ដែលមាន**កម្មករដែលត្រូវបានរ៉ាប់រង** តិចជាង 25 នាក់) វិភាគទានដែលចាប់មានប្រសិទ្ធភាពគឺ 00.378% នៃចំណូលរកបាន។ ក្នុងចំណោមចំនួនវិភាគទានសរុបស្មើនឹង.378% នោះ មានការញែកបែងចែក៖ 34.6% គឺវិភាគទានសម្រាប់ច្បាប់ឈប់សម្រាក ដោយមូលហេតុគ្រួសារ និង 65.4% គឺវិភាគទានសម្រាប់ច្បាប់ឈប់សម្រាកដោយមូលហេតុវេជ្ជសាស្ត្រ។ អង្គភាពអាជីវកម្មដែលត្រូវបានរ៉ាប់រងអាចនឹង កាត់យករហូតដល់ 100% នៃវិភាគទានទាំងនេះពីចំណូលរកបានរបស់បុគ្គលដែលត្រូវបានរ៉ាប់រង។

**ច្បាប់ឈប់សម្រាកដោយមូលហេតុវេជ្ជសាស្ត្រ**

| វិភាគទានដែលត្រូវការសរុប៖ .248% | | | |
|---|---|---|---|
| ______________ (ឈ្មោះអង្គភាព) | នឹងចូលរួមចំណែក | ___% | នៃវិភាគទានសម្រាប់ច្បាប់ឈប់សម្រាកដោយមូលហេតុវេជ្ជសាស្ត្រ |
| | ហើយ | ___% | ដែលនៅសល់នឹងត្រូវបានកាត់យកពីចំណូលរកបានរបស់អ្នក |

**ច្បាប់ឈប់សម្រាកដោយមូលហេតុគ្រួសារ**

| វិភាគទានដែលត្រូវការសរុប៖ .13% | | | |
|---|---|---|---|
| ______________ (ឈ្មោះអង្គភាព) | នឹងចូលរួមចំណែក | ___% | នៃវិភាគទានសម្រាប់ច្បាប់ឈប់សម្រាកដោយមូលហេតុគ្រួសារ |
| | ហើយ | ___% | ដែលនៅសល់នឹងត្រូវបានកាត់យកពីចំណូលរកបានរបស់អ្នក |

ហត្ថលេខាបំពេញ ________________